ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម

german
cooperation
DEUTSCHE ZUSAMMENARBEIT



# គោលការណ៍ណែនាំស្តីអំពី

## ការនាំចេញផ្លែចេកពីប្រទេសកម្ពុជាទៅប្រទេសចិន

បោះពុម្ពដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

## ព័ត៌មានបោះពុម្ព

### សហការបោះពុម្ពផ្សាយដោយ

**អគ្គនាយកដ្ឋានកសិកម្មនៃ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
អគារ៥៤B/៥៩F ផ្លូវលេខ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣
ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ ០២៣ ៨៨៣ ៤២៧
I https://gda.maff.gov.kh/
F https://www.facebook.com/gda.maff.gov.kh

**Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH**

ការិយាល័យចុះបញ្ជី៖
Bonn and Eschborn, Germany

គម្រោង៖ ការគាំទ្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចថ្នាក់តំបន់
នៅអាស៊ី (SRECA)

**កម្ពុជា**
ការិយាល័យ GIZ ASEAN Regional Economic Integration
មជ្ឈមណ្ឌលពាណិជ្ជកម្ម Delano ជាន់ទី២ មហាវិថីសាធារណៈរដ្ឋចិន (១៦៩) កែងផ្លូវលេខ ១៣៤ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ (១២២៥៣) ប្រទេសកម្ពុជា

**ចិន**
Tayuan Diplomatic Office Building 1-14-1
Liangmahe Nanlu No 14
Beijing 100600, Chaoyang District
T + 86 10 8532 1857 F + 86 10 8532 5774
E sreca@giz.de
I www.connecting-asia.org
I www.giz.de/en/worldwide/34101.html

### និពន្ធដោយ/ចងក្រងដោយ៖
Nikolaus Schall

### អ្នកកែសម្រួល
GIZ, GDA

### រចនា/រៀបចំ
Nikolaus Schall

### កម្មសិទ្ធិរូបភាព
GDA
Alibaba.com (Packaging examples)
aam-sutra.blogspot.com (Banana packaging)

### សេចក្តីថ្លែងអំណរគុណ
ឯកសារណែនាំស្តីពីការនាំចេញផ្លែចេកចេញទៅកាន់ប្រទេសចិនត្រូវបានបង្កើតឡើងរួមគ្នាដោយ អគ្គនាយកដ្ឋានកសិកម្ម និងគម្រោង "ការគាំទ្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចថ្នាក់តំបន់នៅអាស៊ី" (SRECA) អនុវត្តដោយអង្គការ GIZ តំណាងឱ្យក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច (BMZ)។

### សេចក្តីអះអាង
ទស្សនៈ និងយោបល់ដែលបានលើកឡើងដោយអ្នកនិពន្ធនៅក្នុងសៀវភៅនេះមិនបានឆ្លុះបញ្ចាំង ឬបង្ហាញពីទស្សនៈរបស់ GIZ ឡើយ។ GIZ ទទួលខុសត្រូវលើខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ។ សៀវភៅណែនាំនេះត្រូវបានចងក្រងជាឧបករណ៍គាំទ្រ។ មិនមានការទទួលខុសត្រូវផ្នែកច្បាប់ណាមួយត្រូវបានទទួលយកសម្រាប់ការខូចខាតណាមួយដែលកើតឡើងពីព័ត៌មានមិនត្រឹមត្រូវនៅក្នុងសៀវភៅណែនាំនេះទេ។

ភ្នំពេញ ខែធ្នូ ឆ្នាំ២០២០

# មាតិកា


**អំពីឯកសារនេះ** ...... ០១

**១. ទិដ្ឋភាពរួមនៃការនាំចេញផ្លែចេកទៅកាន់ប្រទេសចិន** ...... ០២

១.១ ការណែនាំអំពីទីផ្សារផ្លែឈើរបស់ប្រទេសចិន ...... ០២

១.២ គោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកស្ទួយការនាំចេញផ្លែឈើទៅប្រទេសចិន ...... ០២

១.៣ ផលិតកម្មដំណាំចេកនៅប្រទេសកម្ពុជា ...... ០៣

**២. សាវតានៃគោលនយោបាយនាំចេញ និងនាំចូលផ្លែចេករវាងកម្ពុជា-ចិន** ...... ០៥

២.១ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន និង អាស៊ាន-ចិន (កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី FTA) ...... ០៥

២.២ ពិធីសារស្ដីពីលក្ខខណ្ឌតម្រូវការភូតគាមអនាម័យសម្រាប់នាំចេញចេកស្រស់កម្ពុជាទៅកាន់ប្រទេសចិន ...... ០៦

២.៣ គោលនយោបាយស្ដីអំពីការនាំចូល និងនាំចេញទៅកាន់ប្រទេសចិន ...... ០៦

**៣. នីតិវិធីក្នុងការនាំចេញផ្លែចេកតាមជំហាននីមួយៗ** ...... ០៨

៣.១. ការចុះបញ្ជីអ្នកដាំដុះចេក និងទីតាំងវេចខ្ចប់ជាមួយអគ្គនាយកដ្ឋានកសិកម្ម (GDA) ...... ០៩

៣.២ ការទទួលបាននូវវិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ ...... ០៩

៣.៣ ការប្រកាសអំពីវិញ្ញាបនបត្រ និងឯកសារគាំទ្រផ្សេងៗ ...... ១២

៣.៣.១ នីតិវិធីគយ/ការទទួលបានអាជ្ញាបណ្ណនាំចេញ ...... ១២

៣.៣.២ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម ...... ១២

៣.៤ ការដឹកជញ្ជូនផ្លែចេក និងការទូទាត់ប្រាក់ ...... ១៣

៣.៤.១ ការរៀបចំផ្លែចេកសម្រាប់នាំចេញ ...... ១៣

៣.៤.២ ការវេចខ្ចប់ និងបិតស្លាកសញ្ញាលើផ្លែចេក ...... ១៣

៣.៤.៣ ការដឹកជញ្ជូនផ្លែចេកពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិន ...... ១៥

៣.៤.៤ ការបង្កើត និងអភិវឌ្ឍន៍ទំនាក់ទំនងពាណិជ្ជកម្មជាមួយក្រុមហ៊ុនដឹកជញ្ជូនសម្រាប់នាំចេញ ...... ១៨

៣.៤.៥ ភ្នាក់ងារ និងអ្នកចែកចាយ ...... ១៨

៣.៤.៦ នីតិវិធីនៃការទូទាត់ប្រាក់ ...... ២០

**៤. លក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ការនាំចូលទៅប្រទេសចិន** ...... ២២

ទិដ្ឋភាពទូទៅនៃបទប្បញ្ញត្តិ និងច្បាប់ និងតួនាទីរបស់ GACC ...... ២៣

៤.១ ច្បាប់ និងបទប្បញ្ញត្តិ ...... ២៤

៤.២ ការធ្វើអធិការកិច្ច ការធ្វើតេស្ត និងការត្រួតពិនិត្យគុណភាព ...... ២៤

៤.២.១ គោលនយោបាយស្ដីពីកម្រិតសំណល់ជាតិពុលអតិបរមារបស់ប្រទេសចិន ...... ២៥

៤.២.២ បញ្ជីឯកសារដែលត្រូវការសម្រាប់ការដឹកជញ្ជូនផ្លែឈើស្រស់ចូលមកប្រទេសចិន ...... ២៦

៤.៣ ដំណើរការប្រកាសពន្ធគយ និងភូតគាមអនាម័យ ...... ២៧

៤.៤ ការធ្វើអធិការកិច្ចគយ និងភូតគាមអនាម័យ និងនីតិវិធីនៃការធ្វើតេស្ត ...... ២៩

**៥. ការណែនាំសម្រាប់ផលិតកម្ម និងទីផ្សារផ្លែចេក** ...... ៣១

៥.១ ផលិតកម្មចេក..........៣១
៥.២ ការផ្តោតសំខាន់លើគុណភាព..........៣១
៥.៣ ការស្រាវជ្រាវអំពីទីផ្សារ..........៣២
៥.៤ ភាពជាដៃគូក្នុងស្រុក..........៣២
៥.៥ ការធ្វើទីផ្សារ និងការកសាងម៉ាកយីហោ..........៣២
៥.៦ ការធ្វើទីផ្សារ..........៣៣
៥.៧ ការគ្រប់គ្រងហានិភ័យ..........៣៤
**៦. បញ្ជីពិព័រណ៍ពាណិជ្ជកម្មពាក់ព័ន្ធនៅក្នុងប្រទេសចិន**..........៣៤
**៧. ឧបសម្ព័ន្ធ**..........៣៥

## បញ្ជីឧបសម្ព័ន្ធ

១ : ជំហាន/ដំណើរការនៃការដាក់ពាក្យសុំវិញ្ញាបនបត្រភូតគាមអនាម័យ

២: ការប្រកាសពន្ធគយ (កម្ពុជា)

៣: គំរូទម្រង់/ឯកសារសម្រាប់នាំចេញសំខាន់ៗ

៤: ទីភ្នាក់ងាររដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា

៥: បញ្ជីភ្នាក់ងារ និងអាជ្ញាធរនៅកម្ពុជា-ចិន

៦: កម្រិតសំណល់ជាតិពុលអតិបរមាលើផលិតផលចេក

# អំពីឯកសារនេះ

ការកើនឡើងប្រាក់ចំណូល និងជីវភាពប្រជាជនថ្នាក់កណ្តាលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងតម្រូវការដែលមិនចេះរីងស្ងួតរបស់ប្រទេសចិននូវផ្លែឈើស្រស់ដែលដាំដុះក្នុងស្រុក និងនាំចូលដែលមានគុណភាពខ្ពស់។ យោងតាមស្ថិតិផ្លូវការប្រាក់ឈ្នួលរបស់ប្រជាជននៅទីក្រុងប្រចាំឆ្នាំក្នុងប្រទេសចិនជាមធ្យមបានកើនឡើង ១៦៥% ចន្លោះឆ្នាំ២០០៩ ដល់ ២០១៨ ពីប្រមាណ ៣២ ២៤៤ យ័ន (៤ ៥៦៩ ដុល្លារអាមេរិក) ទៅ ៨២ ៤៦១ យ័ន (១១ ៦៨៤ ដុល្លារអាមេរិក)។ ក្នុងរយៈពេលដូចគ្នា តម្លៃនៃការនាំចូលផ្លែឈើស្រស់របស់ចិនបានកើនឡើងជាង ៤៨៧% ពីក្រោម ១,២ពាន់លានដុល្លារអាមេរិកដល់ជាង ៦,៩ ពាន់លានដុល្លារអាមេរិក។ រដ្ឋាភិបាលចិនបានសម្របសម្រួលការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងការនាំចូលទាំងនេះ តាមរយៈការពង្រីកទំនាក់ទំនងពាណិជ្ជកម្មជាមួយបណ្តាប្រទេសនាំចេញផ្លែឈើរួមមានតាមរយៈ ការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការបង្កើនជាលំដាប់នូវចំនួនផ្លែឈើស្រស់ ដែលអនុញ្ញាតឱ្យនាំចូលមកប្រទេសចិនបាន។ នៅឆ្នាំ២០១៨ ប្រទេសចិននាំចូលផ្លែចេកជិត ១១ ០០០ តោន ដែលមានតម្លៃប្រមាណជាង ២០ លានដុល្លារអាមេរិកមកពីប្រទេស និងតំបន់ចំនួន៩ ដែលតំណាងឱ្យមានការកើនឡើង ១១៣% នៃបរិមាណនាំចូល ប៉ុន្តែស្មើត្រឹមតែ ៨,១% នៃតម្លៃកើនឡើងបើធៀបនឹងឆ្នាំ២០១៧[1]។ នៅខែសីហា ឆ្នាំ២០១៨ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើពិធីសារស្តីពីលក្ខខណ្ឌតម្រូវការភូតគាមអនាម័យសម្រាប់ការនាំចេញចេកកម្ពុជាទៅកាន់ប្រទេសចិន។ កិច្ចព្រមព្រៀងនេះចង្អុលបង្ហាញផ្លូវសម្រាប់អ្នកផលិត និងអ្នកនាំចេញចេករបស់កម្ពុជាសម្រាប់ការនាំចេញទៅកាន់ប្រទេសចិន[2]។

គម្រោង "ការគាំទ្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចថ្នាក់តំបន់នៅអាស៊ី (SRECA)" ផ្តួចផ្តើមដោយក្រសួងសហព័ន្ធសម្រាប់សហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ) និងអនុវត្តដោយ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH ធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា ឡាវ ម៉ុងហ្គោលី ចិន និងវៀតណាមក្នុងបរិបទនៃយន្តការសហប្រតិបត្តិការអនុតំបន់ដូចជា គំនិតផ្តួចផ្តើម Greater Tumen (GTI) នៅអាស៊ីខាងកើត ឬតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិននៅតំបន់អាស៊ាន។ ឆ្លើយតបទៅនឹងតម្រូវការរបស់សហគ្រាសកម្ពុជា GIZ បានសហការជាមួយ អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការផ្តល់សៀវភៅណែនាំស្តីពីការនាំចេញផ្លែចេកទៅកាន់ប្រទេសចិន ដើម្បីជួយសម្របសម្រួលដល់ពាណិជ្ជកម្មរវាងប្រទេសទាំងពីរជាពិសេសសម្រាប់អ្នកនាំចេញ។

សៀវភៅណែនាំស្តីពីការនាំចេញចេកទៅកាន់ប្រទេសចិននេះ គឺជាគោលការណ៍ណែនាំលម្អិតសម្រាប់សហគ្រាសឯកជននៅកម្ពុជា ដែលមានបំណងនាំចេញផលិតផលរបស់ពួកគេទៅកាន់ប្រទេសចិន។

---

[1] Tropical Fresh Fruit Exporter's Guide to China, March 2020, Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH, Support of Regional Economic Cooperation in Asia (SRECA), Cambodia

[2] China-Cambodia Protocol on Phytosanitary Requirements for the export of fresh Banana from Cambodia to China

## ១. ទិដ្ឋភាពរួមនៃការនាំចេញផ្លែចេកទៅកាន់ប្រទេសចិន

### ១.១ ការណែនាំអំពីទីផ្សារផ្លែឈើរបស់ប្រទេសចិន

ប្រទេសចិនជាប្រទេសដែលផលិត នាំចូល និងបរិភោគផ្លែឈើស្រស់ធំជាងគេនៅលើពិភពលោក។ កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងប្រាក់ខែជាមធ្យមប្រចាំឆ្នាំនៅតំបន់ទីក្រុងនៅប្រទេសចិនបានកើនឡើងយ៉ាងគំហុកពីប្រមាណ ៤ ៥០០ ដុល្លារអាមេរិកនៅឆ្នាំ២០០៩ រហូតដល់ច្រើនជាង ១១ ០០០ នៅឆ្នាំ២០១៨[3]។ អ្នកប្រើប្រាស់និងអ្នកបរិភោគនៅប្រទេសចិនមានលទ្ធភាពចំណាយច្រើនជាងមុន និងចាប់ផ្តើមចាប់អារម្មណ៍អំពីបញ្ហាសុខភាព។ ការលក់ផ្លែឈើស្រស់បានក្លាយជាចំណុចផ្តោតដ៏សំខាន់នៅតាមបណ្តាទីផ្សារនានានៅប្រទេសចិន។ តម្លៃនៃការនាំចូលផ្លែឈើស្រស់បានកើនឡើងពីក្រោម ១ ២០០ លានដុល្លារអាមេរិកនៅឆ្នាំ២០០៩ រហូតដល់លើសពី ៦ ៩០០លានដុល្លារអាមេរិកនៅឆ្នាំ២០១៨ ដែលក្នុងនោះមានផ្លែឈើជាង ២០០ប្រភេទមកពីប្រទេសចំនួន ២៤ ដែលអនុញ្ញាតឱ្យនាំចូលនៅឆ្នាំ២០១៩។ ទោះបីជាប្រទេសចិនជាប្រទេសផលិតផ្លែចេកធំជាងគេទី២ លើពិភពលោក ប្រទេសមួយនេះក៏ស្ថិតក្នុងបណ្តាប្រទេសដែលនាំចូលចេកច្រើនជាងគេផងដែរ។ ក្នុងឆ្នាំ២០១៨ ប្រទេសចិនបាននាំចូលចេកចំនួនជាង ១,៥ លានតោនដែលស្មើនឹងតម្លៃជិត ៨៩៧លានដុល្លារអាមេរិកពីប្រទេសចំនួន១២ផ្សេងគ្នា។ ប្រទេសហ្វីលីពីនជាអ្នកផ្គត់ផ្គង់ចេកនាំមុខគេទៅកាន់ប្រទេសចិនជាមួយនឹងបរិមាណផ្គត់ផ្គង់ប្រមាណជាង ១លានតោននៅឆ្នាំ២០១៨ ដែលស្មើនឹងតម្លៃជាង ៦០០លានដុល្លារអាមេរិក។ តួលេខនេះស្មើនឹងបរិមាណប្រមាណ ២/៣ នៃបរិមាណនាំចូលសរុបរបស់ចិនដោយគិតទាំងបរិមាណនិងតម្លៃ។ ប្រទេសផ្សេងទៀតដូចជា អេក្វាទ័រ វៀតណាម មីយ៉ាន់ម៉ា និងថៃ ស្ថិតក្នុងចំណោមប្រទេសនាំមុខទាំង៥ ដែលផ្គត់ផ្គង់ចេកទៅឱ្យប្រទេសចិន។ អ្នកផ្គត់ផ្គង់ចេកធំៗទៅឱ្យប្រទេសចិនផ្សេងទៀតនៅឆ្នាំ២០១៨ មានដូចជាប្រទេសឥណ្ឌូនេស៊ី (៩,៨ លានដុល្លារអាមេរិក) និងកូស្តារីកា (៤,៦ លានដុល្លារអាមេរិក)[4]។

### ១.២ គោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកស្ទួយការនាំចេញផ្លែឈើទៅប្រទេសចិន

ប្រទេសកម្ពុជាជាទីផ្សារដ៏ទាក់ទាញសម្រាប់វិនិយោគិនបរទេស ជាពិសេសពីប្រទេសចិនដោយសារទីតាំងភូមិសាស្ត្រ និងគោលនយោបាយនិងបរិយាកាសវិនិយោគអំណោយផល។ ទន្ទឹមនឹងនេះដែរ កម្ពុជាត្រូវតែទាញយកផលប្រយោជន៍ឱ្យអស់ពីលទ្ធភាពពីឱកាសទីផ្សារនេះ និងស្វះស្វែងពង្រីកបរិមាណនាំចេញផលិតផលកសិកម្មដើម្បីជួយបង្កើនកំណើនសេដ្ឋកិច្ចក្នុងប្រទេស។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការគាំទ្រអ្នកផលិត និងនាំចេញផ្លែឈើទីកាន់ទីផ្សារអន្តរជាតិក្នុងគោលបំណងបង្កើនបរិមាណនៃការនាំចេញផ្លែឈើ ដោយមានប្រទេសចិនជាទីផ្សារចម្បងសម្រាប់ការនាំចេញផ្លែចេករបស់ប្រទេសកម្ពុជា។ សេចក្តីសង្ខេបអំពីភ្នាក់ងារសំខាន់ៗរបស់រដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតសម្រាប់ការនាំចេញផ្លែឈើត្រូវបានបញ្ចូលក្នុងឧបសម្ព័ន្ធទី៤នៃឯកសារនេះ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់គោលនយោបាយ និងបទប្បញ្ញត្តិជាច្រើនសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម និងការនាំចេញផលិតកសិកម្មជាក់លាក់។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍថ្នាក់ជាតិ ២០១៩-២០២៣ ជាគោលនយោបាយរួមបញ្ចូលថ្នាក់ជាតិពីរ ដែលលម្អិតអំពីគោលដៅក្នុងការពង្រីកការអភិវឌ្ឍនូវគ្រប់អនុវិស័យកសិកម្មតាមរយៈការបង្កើនផលិតភាព ការធ្វើទំនើបកម្ម និងពាណិជ្ជកម្ម។

[3] Markets for Cambodian Crops with Promising Prospects, Bastiaan Bijl Consultancy GMBH, on behalf of CAVAC, May 2020

[4] Tropical Fresh Fruit Exporter's Guide to China, March 2020, Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH, Support of Regional Economic Cooperation in Asia (SRECA), Cambodia

ការអភិវឌ្ឍវិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជាត្រូវបានគូសបញ្ជាក់នៅក្នុង **ផែនការយុទ្ធសាស្ត្រវិស័យកសិកម្ម ២០១៩-២០២៣** និង**ផែនការមេសម្រាប់វិស័យកសិកម្មឆ្នាំ២០៣០** ដែលមានបំណងលើកកម្ពស់ការប្រកួតប្រជែង កំណើនប្រកបដោយបរិយាប័ន្ន និងវិស័យកសិកម្មទំនើបប្រកបដោយចីរភាព និងភាពបត់បែន[5]។

ជាពិសេស នៅក្នុងអនុវិស័យដំណាំ **ផែនការមេសម្រាប់ផលិតកម្មដំណាំឆ្នាំ២០១៦-២០៣០** ប្រមើលមើលកម្ពុជាជា "ប្រភពដែលអាចទុកចិត្តបានសម្រាប់ផលិតដំណាំដែលមានគុណភាពខ្ពស់ សុវត្ថិភាព និងមានការប្រកួតប្រជែងនៅក្នុងសេដ្ឋកិច្ចសកលលោក ទន្ទឹមនឹងការធានាបាននូវបរិមាណគ្រប់គ្រាន់នៃអាហារដែលមានសុវត្ថិភាពដើម្បីបំពេញនូវសុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភនៃប្រជាជនខ្លួនប្រកបដោយចីរភាព និងបត់បែនតាមលក្ខខណ្ឌអាកាសធាតុ"។ នៅក្រោមផែនការគោលនេះ ដំណាំសក្តានុពលចំនួន ៨ និងខ្សែច្រវ៉ាក់ផលិតកម្មរបស់ដំណាំទាំងនោះត្រូវបានកំណត់សម្រាប់ការបញ្ជាក់បន្ថែមទៅលើគោលនយោបាយសម្រាប់ការធ្វើអន្តរាគមន៍។

ដោយទទួលស្គាល់អំពីភាពសំខាន់របស់អនុវិស័យសាកវប្បកម្ម និងមានការតាំងចិត្តក្នុងការលើកកម្ពស់អនុវិស័យនេះ រាជរដ្ឋាភិបាលកំពុងបង្កើតនូវ **យុទ្ធសាស្ត្រសាកវប្បកម្ម** ដែលមាន ៨សមាសភាគចូលរួម ដែលរួមមានការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការធ្វើឱ្យប្រសើរឡើងនូវផលិតកម្មនិងផលិតភាព ការគ្រប់គ្រងក្រោយប្រមូលផល ទីផ្សារនិងការនាំចេញ ការកែច្នៃនិងបន្ថែមតម្លៃ ការអភិវឌ្ឍនធនធានមនុស្ស ក្រុមអ្នកផលិតនិងអ្នកប្រើប្រាស់/អ្នកបរិភោគ និងការសហការណ៍ និងចងបណ្តាញជាមួយស្ថាប័នពាក់ព័ន្ធដទៃទៀត។

នៅកម្រិតផលិតកម្ម **ច្បាប់សហគមន៍កសិកម្ម** និង **អនុក្រឹត្យស្តីពីកសិកម្មកិច្ចសន្យា** មានបំណង "ពង្រឹងការទទួលខុសត្រូវ និងកសាងទំនុកចិត្ត" រវាងកសិករ និងអ្នកទិញផ្អែកទៅលើគោលការណ៍ "សមភាព និងភាពយុត្តិធម៌"។ ការអនុវត្តកសិកម្មកិច្ចសន្យា គឺដើម្បីធានាតម្លៃ គុណភាព និងបរិមាណនៃការផ្គត់ផ្គង់ផលិតផលកសិកម្ម ហើយ "បង្កើនការទិញ ការកែច្នៃ និងការនាំចេញផលិតផលកសិកម្ម"។ នៅក្រោមអនុក្រឹត្យនេះ កសិករធ្វើការផ្ទាល់ជាមួយអ្នកទិញក្រោមការសម្របសម្រួលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បន្ថែមពីលើនេះទៀត **ប្រកាសស្តីពីការអនុវត្តកសិកម្មល្អ** ក៏ត្រូវចងក្រងផ្អែកទៅលើបទដ្ឋានការអនុវត្តកសិកម្មល្អរបស់បណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលចេញវិញ្ញាបនបត្របញ្ជាក់គុណភាពបន្លែ ផ្លែឈើ និងកសិដ្ឋានទាំងឡាយ។ មកដល់សព្វថ្ងៃ នៅប្រទេសកម្ពុជាមានកសិដ្ឋានប្រមាណជា៥០ ដែលទទួលបានវិញ្ញាបនបត្រ ហើយភាគច្រើនជាកសិដ្ឋានដាំដុះផ្លែឈើ។ **គោលនយោបាយផ្សព្វផ្សាយកសិកម្ម** ដែលបានអនុវត្តតាំងពីឆ្នាំ២០១៥ មានបំណងគាំទ្រកសិករដើម្បីទទួលបាននូវចំណេះដឹង ជំនាញ ព័ត៌មាន និងបច្ចេកវិទ្យាកាន់តែទូលំទូលាយដើម្បីពង្រឹងផលិតភាពកសិកម្ម ពិពិធកម្ម និងពាណិជ្ជកម្ម។

ពិធីសាររវាងកម្ពុជា-ចិនស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេញចេកស្រស់ពីកម្ពុជាទៅកាន់ប្រទេសចិន ជាឧទាហរណ៍ដ៏ល្អមួយដែលបង្ហាញអំពីការសម្របសម្រួលរបស់រដ្ឋាភិបាល និងការគាំទ្រដល់អ្នកដាំដុះ និងអ្នកនាំចេញទៅកាន់ទីផ្សារប្រទេសចិន។

## ១.៣ ផលិតកម្មដំណាំចេកនៅប្រទេសកម្ពុជា

ចេកមានឈ្មោះវិទ្យាសាស្ត្រហៅថា *Musa supientum* (ចេកអំបូងលឿង)។ ប្រជាកសិករកម្ពុជាមានទម្លាប់ដាំដុះប្រភេទចេកផ្សេងៗគ្នានៅក្នុងដីភូមិរបស់ពួកគាត់។ ចេកពងមាន់ (*Musa Aromatica*) ជាចេកដែលគេនិយមបរិភោគ និងប្រើប្រាស់ដោយប្រជាជនកម្ពុជា[6]។ ចំណែកចេកណាំវ៉ាត្រូវបានដាំដុះគ្រប់ទីកន្លែងដោយកសិករ។ ប្រភេទចេកមួយទៀត

[5] Source: GIZ; Mapping Actors in Trade/Export of Agriculture Produce in Cambodia, 31 July 2020, BDTrus consultancy

[6] https://chanthol.wordpress.com/2009/01/16/chicken-egg-banana-musa-aromatica-the-national-fruit-of-the-kingdom-of-cambodia/

គឺចេកអំបូង[7] ដែលត្រូវបានដាំដុះនៅតំបន់ជាច្រើននៃប្រទេសកម្ពុជា។ ចេកប្រភេទនេះស្រដៀងទៅនឹងចេកអំបូងលឿង ដែលជាពូជសម្រាប់នាំចេញដែរ។

ផលិតកម្មដំណាំចេកនៅប្រទេសកម្ពុជាមានការកើនឡើងជាបន្តបន្ទាប់ក្នុងឆ្នាំថ្មីៗកន្លងទៅនេះ។ យោងទៅតាមព័ត៌មានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញថា កម្ពុជាបាននាំចេញចេកអំបូងលឿងចំនួន ១៥៧ ៨១២ តោន នៅឆ្នាំ២០១៩ និង ១៤៧ ៧៦០ តោនក្នុងរយៈពេល ៦ខែដំបូងនៃឆ្នាំ ២០២០[8] ហើយតួលេខនាំចេញបានកើនឡើងរហូតដល់ ១៦៧ ៧៥៤ តោន គិតត្រឹមខែកក្កដា ឆ្នាំ២០២០[9]។ ជាមួយនឹងផលិតកម្មរបស់ក្រុមហ៊ុន ដែលបានចុះបញ្ជីទាំងឡាយដែលគ្របដណ្តប់ផ្ទៃដីជាង ៨ ០០០ហិកតា និង ២១រោងចក្រវេចខ្ចប់ ការនាំចេញចេកទៅកាន់ប្រទេសចិនត្រូវបានរំពឹងថានឹងមានការកើនឡើងទ្វេដងនៅឆ្នាំ២០២០[10]។ ជារួម ប្រទេសចិនត្រូវការផ្លែចេកប្រមាណ ២លានតោន ក្នុងមួយឆ្នាំពីប្រទេសផ្សេងៗ ហេតុនេះជាសក្តានុពលយ៉ាងខ្លាំងសម្រាប់វិនិយោគិនទាំងឡាយក្នុងការបង្កើនការវិនិយោគ និងផលិតកម្មដំណាំចេកក្នុងប្រទេសកម្ពុជា។ តំបន់ផលិតចេកអំបូងលឿងសំខាន់រួមមាន ខេត្តកំពត កំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគីរី និងត្បូងឃ្មុំ។

ផលិតកម្ម និងការនាំចេញផ្លែចេកដែលមានកំណើនយ៉ាងលឿន គឺដោយសារមានកសិដ្ឋាន និងក្រុមហ៊ុនធំៗ រួមនឹងការវិនិយោគរបស់វិនិយោគិនចិន និងវៀតណាម។ យោងទៅតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកសិដ្ឋាន និងទីតាំងវេចខ្ចប់ចេកចំនួន១៥ នៅប្រទេសកម្ពុជាត្រូវបានទទួលស្គាល់ដោយប្រទេសចិន។ នាពេលបច្ចុប្បន្ន ផ្ទៃដីផលិតកម្មប្រភេទចេកដែលប្រទេសចិនអនុញ្ញាតសម្រាប់នាំចេញទៅប្រទេសខ្លួនគ្របដណ្តប់ជិត ៥ ០០០ហិកតា ជាមួយនឹងផ្ទៃដីផលិតកម្មប្រចាំឆ្នាំជិត ៣០០ ០០០តោន។ កម្ពុជាជាប្រទេសដ៏សមស្របសម្រាប់ឧស្សាហកម្មចេកបែបទំនើប ជាមួយលក្ខខណ្ឌដ៏ឥតខ្ចោះនៃអាកាសធាតុ គុណភាពដី និងពលកម្ម។ ឧស្សាហកម្មចេករបស់ប្រទេសកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយទីផ្សារ បច្ចេកវិទ្យា និងទុនរបស់ប្រទេសចិន។ ដោយសារតែលទ្ធភាពក្នុងការបំពេញបាននូវចន្លោះទីផ្សារក្នុងប្រទេសចិន កម្ពុជានឹងក្លាយជាអ្នកផ្គត់ផ្គង់មួយក្នុងចំណោមអ្នកផ្គត់ផ្គង់ចេកធំៗទៅកាន់ប្រទេសចិននាពេលអនាគត[11]។ លើសពីនេះទៀត ប្រទេសកម្ពុជាកំពុងរីករាយនឹងផលិតកម្មចេកដែលស្ទើរតែគ្មានការប៉ះពាល់ពីជំងឺផ្សិតហ្វ៊ុយសារីយ៉ូមស្រពោនលឿងស្លឹក(Fusarium Wilt) ដែលជាជំងឺបំផ្លាញធ្ងន់ធ្ងរប៉ះពាល់ដល់ប្រទេសផលិតចេកជាច្រើនលើសកលលោក។ ទន្ទឹមពេលដែលប្រទេសផលិតចេកផ្សេងៗទៀតមួយចំនួនកំពុងតែរងគ្រោះពីការកើនឡើងនៃកម្រិតឆ្លងជំងឺប្រភេទនេះ ប្រទេសកម្ពុជានៅមានលក្ខណៈអំណោយផលច្រើនក្នុងករណីនេះ[12]។

---

7 https://www.thespruce.com/types-of-bananas-4018334

8 Ibid.

9 MAFF Minister's official Facebook page,

10 MAFF Minister's official Facebook page,

11 Source: https://www.producereport.com/article/13-new-fruit-varieties-admitted-china-2019-total-now-over-200

12 Source: https://www.producereport.com/article/cambodian-bananas-achieve-permission-import-china

រូបភាពទី១ ៖ ចេកអំបូងលឿង (ពូជសម្រាប់នាំចេញ)






## ២. សាវតានៃគោលនយោបាយនាំចេញ និងនាំចូលផ្លែចេករវាងកម្ពុជា-ចិន

### ២.១ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន និង អាស៊ាន-ចិន (កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី FTA)

ប្រទេសកម្ពុជា និងចិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ដោយជោគជ័យកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០។ កិច្ចព្រមព្រៀងនេះនឹងផ្តល់លទ្ធភាពឱ្យប្រទេសកម្ពុជាចូលទៅកាន់ទីផ្សារកាន់តែទូលំទូលាយ។ លើសពីនេះទៀត ទំហំពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរនឹងត្រូវបានពង្រីកបន្ថែមទៀត។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) គឺជាគំនិតផ្តួចផ្តើមដ៏សំខាន់មួយសម្រាប់ប្រទេសកម្ពុជាក្នុងការចូលរួមកាន់តែស៊ីជម្រៅជាមួយប្រទេសចិនទាក់ទងនឹងការជំរុញពាណិជ្ជកម្មទ្វេភាគី និងការវិនិយោគផ្ទាល់ពីបរទេស(FDI)។ អត្ថប្រយោជន៍សំខាន់ពីរដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនឹងផ្តល់ឱ្យប្រទេសកម្ពុជារួមបញ្ចូលទាំងអ្នកនាំចេញចេក។ អត្ថប្រយោជន៍សំខាន់ទី១ សេដ្ឋកិច្ចប្រទេសកម្ពុជាបានរីកចម្រើនយ៉ាងឆាប់រហ័ស ហើយជាពិសេសការនាំចេញផលិតផលកសិកម្មនឹងទទួលបានអត្ថប្រយោជន៍ ចាប់ពីការទទួលបានទីផ្សារថ្មីៗទៅកាន់ទីផ្សារដែលកំពុងកើនឡើងនៅប្រទេសចិន។ អត្ថប្រយោជន៍សំខាន់ទី២ កិច្ចព្រមព្រៀងនឹងជំរុញលំហូរពាណិជ្ជកម្ម និងការវិនិយោគកាន់តែខ្លាំងឡើងរវាងកម្ពុជា និងចិនតាមរយៈការកាត់បន្ថយ ឬការដកចេញរបាំងពន្ធ ឬមិនមែនរបាំងពន្ធ។ តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ពុំមានការបង់ពន្ធនាំចូលផ្លែឈើស្រស់ទៅកាន់ប្រទេសចិននោះទេ។ នៅទីបំផុតប្រទេសកម្ពុជានឹងទទួលបានអត្ថប្រយោជន៍ពីផលិតផលចម្រុះ និងមានតម្លៃទាបជាងមុនសម្រាប់នាំចូលទីផ្សារក្នុងស្រុក។ ស្របពេលជាមួយគ្នានេះ ពាណិជ្ជកម្ម និង ការវិនិយោគនឹងផ្តល់ឱ្យអ្នកប្រើប្រាស់ និងអាជីវកម្មផ្សេងៗនូវលទ្ធភាពទទួលបានទំនិញ និងសេវាកម្មដែលមានតម្លៃសមរម្យ ពាណិជ្ជកម្ម និងការវិនិយោគនឹងជំរុញកំណើនសេដ្ឋកិច្ចបន្តទៀត ដែលនឹងជួយប្រទេសកម្ពុជា ឱ្យសម្រេចគោលដៅរបស់ខ្លួន ដើម្បីក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ។

អត្ថប្រយោជន៍ដែលគេរំពឹងទុកសម្រាប់ប្រទេសចិន គឺជួយប្រទេសចិនពង្រឹងចំណងទាក់ទងរបស់ខ្លួនជាមួយនឹងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតរួមទាំងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍។ ប្រទេសកម្ពុជាទទួលបានអត្រាកំណើនសេដ្ឋកិច្ច ៧% ប្រចាំឆ្នាំ ដែលនឹងជួយលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចដ៏ទូលំទូលាយបន្ថែមទៀតនៅក្នុងតំបន់ ហើយនឹងអនុញ្ញាតឱ្យក្រុមហ៊ុនចិនដើរតួនាទីកាន់តែសកម្មនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងតំបន់ដែលមានទំនាក់ទំនងនយោបាយ និងសេដ្ឋកិច្ចរឹងមាំជាមួយប្រទេសចិន។